ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ......១១៣/២៥.........ក.ប/ប្រ.ក.ស.ជ.ក

# ប្រកាស
# ស្តីពី
# សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន
# រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីជូនដំណឹងលេខ ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារ ត្រូវប្រើ និងរក្សាទុកឱ្យបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ដែលមានកូដឆ្លើយតបរហ័ស (QR Code) ដូចមានគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះដោយត្រូវទាញចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារតាមរយៈគេហទំព័រ https://lacms.mlvt.gov.kh។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២ .-**

សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន មានមុខងារសម្រាប់អធិការការងារធ្វើកំណត់សម្គាល់អំពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងាររបស់សហគ្រាស គ្រឹះស្ថាន ដែលម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវពិនិត្យ និង/ឬកែតម្រូវការអនុវត្តរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងការសង្កេត ការផ្តល់ដំបូន្មាន ឬការដាក់កំហិត ព្រមទាំងវិធានការផ្សេងទៀតរបស់អធិការការងារ នៅរាល់ពេលចុះត្រួតពិនិត្យ។

**ប្រការ៣ .-**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវរក្សាទុកឯកសារពាក់ព័ន្ធនឹងការប្រើប្រាស់សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននៅក្នុងទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ។ បន្ទាប់ពីការបិទបញ្ចប់ការប្រើប្រាស់សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន និយោជកត្រូវរក្សាទុកឱ្យគង់ក្នុងរយៈពេល ៣ (បី) ឆ្នាំ។

នៅពេលប្រើប្រាស់សៀវភៅបញ្ជីប្រចាំគ្រឹះស្ថានគ្រប់ទំព័រទាំងអស់ហើយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវទាញយកសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានថ្មី ដោយអនុវត្តតាមបែបបទ និងនីតិវិធីដូចមានកំណត់ក្នុងប្រការ១ ខាងលើ។

អធិការការងារអាចត្រួតពិនិត្យសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន និងឯកសារពាក់ព័ន្ធនៅគ្រប់ពេលវេលា។

**ប្រការ៤ .-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងការផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៥ .-**

ប្រកាសលេខ ២៦៨ សកបយ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១១៣/២៥ កស/ប្រក.អភក ចុះថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២៥ ស្ដីពី
សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅ
# បញ្ជីប្រចាំគ្រឹះស្ថាន

ថ្ងៃ........................ខែ..............ឆ្នាំ..............ស័ក ព.ស.........
........................ថ្ងៃទី............ខែ............ឆ្នាំ...............

សៀវភៅទី.......

-នាមករណ៍សហគ្រាស ៖.....................................................

-សកម្មភាពអាជីវកម្ម ៖.....................................................

-អាសយដ្ឋាន ៖ ផ្ទះលេខ.......ផ្លូវ..........ភូមិ..........

ក្រុម..........ឃុំ/សង្កាត់...................

ក្រុង/ស្រុក/ខណ្ឌ............................

រាជធានី/ខេត្ត...............................

-ឈ្មោះម្ចាស់ ឬនាយក ៖.....................................................

-កាលបរិច្ឆេទនៃការចេញសៀវភៅបញ្ជី ៖........................................

ថ្ងៃ.......................ខែ.............ឆ្នាំ......... .....ស័ក ព.ស.........

......................ថ្ងៃទី............ខែ...........ឆ្នាំ.............

QR Code

**QR Code**